ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី៣ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨

រៀបចំដោយ៖ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយ៖ ថវិកាជាតិ

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៣ សម្រាប់ឆ្នាំ២០១៨ ក្រោមការដឹកនាំរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើការងារមេរោគអេដស៍ និងជំងឺអេដស៍។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ដើម្បីពិនិត្យមើលរបាយការណ៍វឌ្ឍនភាព និងទិសដៅបន្តក្នុងការឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ ព្រមទាំងពិភាក្សា សម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈ ដូចខាងក្រោម៖

-មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំ

-របាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-បទបង្ហាញពីស្ថានភាពបច្ចុប្បន្នរបស់អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ដោយបណ្តាញ CPN+

-បទបង្ហាញពីបញ្ហាប្រឈមរបស់ក្រុមបុរសស្រលាញ់បុរស ក្នុងការឈានឆ្ពោះទៅបញ្ចប់បញ្ហាអេដស៍ ដោយអង្គការ FHI360។

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណ ដល់សមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។

**ប្រធានបទទី១**: **ឯកឧត្តមវេជ្ជបណ្ឌិត ជា ប៉ោ** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនពីរបាយការណ៍សង្ខេបរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានធ្វើក្នុងខែមីនា ឆ្នាំ២០១៨ ដូចខាងក្រោម៖

- នារសៀលថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៨ នៅខេត្តកោះកុង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានប្រារព្ធពិធីអបអរសាទរខួបលើកទី១០៧ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០១៨ ក្រោមប្រធានបទ " ស្ត្រីរួមគ្នារក្សាសន្តិភាព ដើម្បីអភិវឌ្ឍន៍ជាតិ "។

- ថ្ងៃទី៦ ដល់ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៨ នៅខេត្តកោះកុង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើការងារដែលបានអនុវត្តក្នុងឆ្នាំ២០១៧ ព្រមទាំងពិនិត្យផែនការសម្រាប់អនុវត្តការងារក្នុងឆ្នាំ២០១៨ និងពេលខាងមុខបន្តទៀត។
- ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំពិភាក្សាជាមួយនាយកដ្ឋានសុខាភិបាលក្រសួងការពារជាតិ ទីចាត់ការសុខាភិបាលអគ្គបញ្ជាការនៃកងយោធពលខេមរភូមិន្ទ និងអង្គការមូលនិធិថែទាំសុខភាពអ្នកជំងឺអេដស៍ប្រចាំកម្ពុជា (AHF)។
- ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំការពិភាក្សាការងារជាមួយអង្គការដៃគូ ដើម្បីពិនិត្យមើលលទ្ធភាព និងសម្របសម្រួលរកមធ្យោបាយគាំទ្រ សម្រាប់ដំណើរការអនុវត្តសកម្មភាពរបស់ក្រុមការងារបច្ចេកទេសប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងចំណោមក្រុមប្រជាជនប្រឈមមុខខ្ពស់ ជាពិសេសក្រុមបុរសរួមភេទជាមួយបុរស និងក្រុមស្រីស្រស់។
- ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានអញ្ជើញជាអធិបតីបើកសិក្ខាសាលាប្រចាំឆ្នាំ (Retreat) របស់គណៈកម្មាធិការសម្របសម្រួលជំនួយមូលនិធិសកល (CCC: Country Coordinating Committee) នៅខេត្តបាត់ដំបង ដោយមានការចូលរួមពីតំណាងស្ថាប័នសាសនា ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ តំណាងប្រជាជនរងផលប៉ះពាល់ វិស័យឯកជន មន្ទីរសុខាភិបាលខេត្ត និងទីប្រឹក្សាបច្ចេកទេស ចំនួន៣៥នាក់។
- ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានអញ្ជើញចុះសួរសុខទុក្ខអ្នកផ្ទុកមេរោគអេដស៍ នៅឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង ដោយមានការចូលរួមពីប្រជាពលរដ្ឋ ដែលទទួលបានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ តំណាងមន្ទីរពេទ្យបង្អែករកា និងអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍។
- នារសៀលថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានអញ្ជើញជាអធិបតីទទួលអំណោយអាហារបំប៉នសុខភាពខេម ប្រូប៊ីយូទិក (KEM Probiotic) ពីមូលនិធិគីណាល់

  តំណាងដោយលោកឱសថបណ្ឌិត **ហៃ លីអ៊ាង** ប្រធានមូលិធិ និងជាប្រធានសហគ្រាសផលិតឱសថ ប៉េ ប៉េ អឹម និងក្រុមហ៊ុន ខនហ្វីរេល ចំនួន ១០០៨ដប (មួយដបមានចំណុះ២០០មីលីលីត្រ) ដើម្បីចែកជូនបន្តដល់បងប្អូនដែលរស់នៅជាមួយមេរោគអេដស៍។

- ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ ក្រសួងបរិស្ថាន បានសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រៀបចំកម្មវិធីអបអរសាទរ "ការប្តេជ្ញារបស់ក្រសួងបរិស្ថានចូលរួមបញ្ចប់អេដស៍នៅឆ្នាំ២០២៥" ក្រោមអធិបតីភាព ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន។
- ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ក្រុមការងារបច្ចេកទេសថ្នាក់ជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសរួមភេទជាមួយបុរស និងស្រីស្រស់។

**<u>ផែនការសកម្មភាព និងទិសដៅសម្រាប់អនុវត្តបន្ត</u>**

- កំពុងកែសម្រួល និងផ្ទៀងឈ្មោះ អាសយដ្ឋាន និង E-mail ឡើងវិញរបស់សមាសភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្តទាំង២៥។
- រៀបចំនីតិវិធីរដ្ឋបាល ដើម្បីធ្វើសិក្ខាសាលាស្តីពីការរៀបចំផែនការសកម្មភាពឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមប្រជាជនប្រឈមមុខខ្ពស់នៅរាជធានីភ្នំពេញ។
- រៀបចំនីតិវិធីរដ្ឋបាលដើម្បីធ្វើសិក្ខាសាលាស្តីពីការរៀបចំផែនការយុទ្ធសាស្ត្របង្ការ ថែទាំ និងគាំទ្រ សម្រាប់ឆ្នាំ២០១៩-២០២០ នៅខេត្តកំពត។
- សម្របសម្រួលការរៀបចំរបាយការណ៍វឌ្ឍនភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ទៅអង្គការសហប្រជាជាតិឆ្នាំ២០១៨ (GARPR 2018)។
- រៀបចំក្រុមការងារដើម្បីពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្រជាតិលើកទី៤ និងរៀបចំផែនការយុទ្ធសាស្ត្រជាតិលើកទី៥។

ក្រោយពីបង្ហាញចប់ **ឯកឧត្តមប្រធានអង្គប្រជុំ** ក៏បានស្នើឱ្យបន្ថែមនូវសកម្មភាពដែលសមាជិកក្រុមការងារបានអនុវត្តកន្លងមក សម្រាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖

- តំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចៈ បានចុះផ្សព្វផ្សាយ និងបញ្ជ្រាបពីបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ បានចំនួន៥លើក៖
    - ✓ នៅកងពលតូចអន្តរាគមន៍លេខ៥ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ មានអ្នកចូលរួមចំនួន៣៥០នាក់ ស្រីចំនួន៨នាក់។
    - ✓ នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មានអ្នកចូលរួមចំនួន៥៣៦នាក់ ស្រីចំនួន១៧៦នាក់។
    - ✓ នៅស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ មានអ្នកចូលរួមចំនួន៥៤៤នាក់ ស្រីចំនួន១៨៨នាក់។

- ✓ នៅសាលានគរបាលជាតិមិត្តភាពកម្ពុជា វៀតណាម មានអ្នកចូលរួមចំនួន២៥០នាក់ ស្រីចំនួន៤នាក់។
- ✓ នៅវិទ្យាល័យកំពង់ស្ពឺ ខេត្តកំពង់ស្ពឺ អ្នកចូលរួមចំនួន៥១៥នាក់ ស្រីចំនួន២៦៥នាក់។

➤ តំណាងក្រសួងព័ត៌មានៈ បានបញ្ជ្រាបសារអប់រំពីបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងសន្និបាតប្រចាំឆ្នាំ២០១៧ និងលើកទិសដៅសម្រាប់ឆ្នាំ២០១៨ របស់ក្រសួង ដោយមានអ្នកចូលរួម៣៥០នាក់ កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨។

➤ តំណាងក្រសួងការពារជាតិៈ បានចុះផ្សព្វផ្សាយអប់រំពីបញ្ហាមេរោគអេដស៍ និងធ្វើតេស្តឈាមរកមេរោគអេដស៍ នៅខេត្តបាត់ដំបង (កងពលលេខ៥២ និងកងពលលេខ៥៣) បានចំនួន៣៨៩នាក់ តេស្តវិជ្ជមានចំនួន៤នាក់។

➤ តំណាងក្រសួងអភិវឌ្ឍន៍ជនបទៈ បានចុះអប់រំផ្សព្វផ្សាយពីបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ ដល់ប្រជាពលរដ្ឋទូទៅនៅឃុំពាមជីលាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ដោយមានអ្នកចូលរួមចំនួន៥៧នាក់ ស្រីចំនួន៤៥នាក់។

➤ តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគៈ
- ✓ បានប្រជុំបណ្តាញការងារអនុវត្ត Boosted-IACM នៅខេត្តសៀមរាប ក្នុងគោលបំណងពង្រឹងបណ្តាញការងារ ពិនិត្យមើលការប្រឈម បញ្ហាលំបាក និងពិភាក្សារកដំណោះស្រាយឱ្យបានសមស្រប។
- ✓ បានផលិតឯកសារចំនួន២ៈ
  - ឯកសារស្តីពីយុទ្ធវិធីបង្ការ ថែទាំ និងព្យាបាលបន្តដល់ក្រុមប្រឈមមុខខ្ពស់ ដោយបានការអនុម័តពីក្រសួងសុខាភិបាល កាលពីខែមករា ឆ្នាំ២០១៨។
  - ឯកសារស្តីពី Peer Driven Intervention Plus (PDI+) ដើម្បីស្វែងរកករណីឆ្លងមេរោគអេដស៍ថ្មីតាមរយៈមិត្តភ័ក្រ្ត ដោយបានការអនុម័តពីក្រសួងសុខាភិបាល នៅខែមីនា ឆ្នាំ២០១៨។

**ប្រធានបទទី២ៈ** បទបង្ហាញពីសកម្មភាពទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ របស់បណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍នៅកម្ពុជា (CPN+) ជម្រាបជូនដោយលោក **សឿម សុផល** តំណាងបណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍នៅកម្ពុជាៈ

-អំពីបណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍នៅកម្ពុជា ជាបណ្តាញថ្នាក់ជាតិដែលបានបង្កើតឡើងដោយក្រុមអ្នករស់នៅជាមួយមេរោគអេដស៍ និងអ្នករងផលប៉ះពាល់។ ក្នុងគោលបំណងធ្វើឱ្យ

បងប្អូនអ្នករស់នៅជាមួយមេរោគអេដស៍ រស់នៅប្រកបដោយសុខភាពល្អ និងភាពវិជ្ជមានក្នុងសង្គមជាតិ។

-Community Action Approach Framework (CAAF) ជាសកម្មភាពច្របាច់បញ្ចូលគ្នារវាង B-IACM ផ្តោតសំខាន់ទៅលើការបោះបង់ចោលការព្យាបាល ដែលតម្រូវឱ្យមានបុគ្គលម្នាក់ស្គាល់ពួកគាត់ច្បាស់ សម្រាប់តាមរកពួកគាត់។

-CAAF ធ្វើនៅខេត្តចំនួន៤ គឺខេត្តកំពង់ធំ ខេត្តកោះកុង ខេត្តព្រះវិហារ និងខេត្តស្វាយរៀង។

-មានការលំបាកក្នុងការសម្របសម្រួល និងស្វែងរកអ្នកបោះបង់ ពេលពួកគាត់មិនមកសេវាតាមការណាត់របស់គ្រូពេទ្យ ដោយសារពុំមានថវិកាសម្រាប់ធ្វើសកម្មភាព។

-ជាសំណូមពរពីតំណាងបណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍នៅកម្ពុជា សូមកុំបោះបង់ចោលពួកគាត់ នៅពេលដែលថវិកាសម្រាប់សកម្មភាពកំពុងថយចុះជាលំដាប់។

**ប្រធានបទទី៣៖** បទបង្ហាញពីទិសដៅក្នុងការបញ្ចប់ការចម្លងមេរោគអេដស៍ ក្នុងចំណោមក្រុមបុរសរួមភេទជាមួយបុរស និងក្រុមស្រីស្រស់ក្នុងឆ្នាំ២០២០ បង្ហាញជូនដោយ **លោក ផល សុផាត** តំណាងអង្គការ FHI 360 បានធ្វើការបកស្រាយដូចខាងក្រោម៖

- ✓ ២០១៦ អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមក្រុមស្រីស្រស់ (TG women) មានអត្រា 5.9% ទូទាំងប្រទេសកម្ពុជា។ នៅក្នុងខេត្តបន្ទាយមានជ័យមាន (11.7%) ខេត្តសៀមរាបមាន(11.3%) ជាខេត្តដែលមានអត្រាប្រេវ៉ាឡង់ខ្ពស់ជាងគេ។ ចំពោះរាជធានីភ្នំពេញមានអត្រាប្រេវ៉ាឡង់ (6.5%) និងខេត្តបាត់ដំបងមានអត្រា (5.3%) ប៉ុណ្ណោះ។
- ✓ ២០១៤ អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមបុរសរួមភេទជាមួយបុរស (MSM) មានអត្រាប្រេវ៉ាឡង់ (2.3%) ទូទាំងប្រទេសកម្ពុជា។ ចំពោះខេត្តសៀមរាបមានអត្រាប្រេវ៉ាឡង់ (5.9%) រាជធានីភ្នំពេញមានអត្រាប្រេវ៉ាឡង់ (3.0%) អត្រាប្រេវ៉ាឡង់នៅខេត្តបាត់ដំបង និងខេត្តកណ្តាលមាន (0.5%) ប៉ុណ្ណោះ។
- ✓ លទ្ធផលពីការវាយតម្លៃលើកម្មវិធីអឹមស្កាយ និងកម្មវិធីស្រីស្រស់ របស់ University Research co.,(URC)
  - ៨៩%នៃបុរសរួមភេទជាមួយបុរសនៅសហគមន៍បានទទួលការអប់រំ និងទទួលបានសម្ភារអប់រំពីអ្នកអប់រំតាមមូលដ្ឋាន។
  - ៨៤%នៃក្រុមបុរសរួមភេទជាមួយបុរសបានបញ្ជូនទៅទទួលសេវា VCCT STI តាមកម្មវិធីអឹមស្កាយ។
  - ៦៦%នៃបុរសរួមភេទជាមួយបុរស បានចូលរួមជាមួយកម្មវិធីអឹមស្កាយ បានរាយការណ៍ថាប្រើប្រាស់ស្រោមអនាម័យជាមួយដៃគូរួមភេទ។
  - ៥៤%នៃបុរសរួមភេទជាមួយបុរស ដែលមិនបានចូលក្នុងកម្មវិធីអឹមស្កាយ បានរាយការណ៍ថាមិនបានប្រើស្រោមអនាម័យជាមួយដៃគូរួមភេទ។

- ៨៣%នៃក្រុមស្រីស្រស់ បានរាយការណ៍ថាបានទទួលសេវាពិនិត្យជំងឺកាមរោគ
- ៨៧%នៃក្រុមស្រីស្រស់ បានទទួលសេវាធ្វើតេស្តឈាមរកមេរោគអេដស៍

✓ ដើម្បីសម្រេចបានគោលដៅ ៩០-៩០-៩០ នៅឆ្នាំ២០២០ និងគោលដៅ ៩៥-៩៥-៩៥ ឆ្នាំ ២០២៥ រួមមាន៖

- អនុវត្តតាមការឆ្លើយតបនឹងគោលការណ៍ណែនាំជាតិស្តីពីជំងឺអេដស៍ ៩០-៩០-៩០ រហូតដល់ឆ្នាំ២០២០ ដល់ឆ្នាំ២០២៥។
- គោលការណ៍ណែនាំជាតិរួមបញ្ចូលគ្នាស្តីអំពីសេវាធ្វើតេស្តឈាមរកមេរោគនៅកម្ពុជា
- ការណែនាំរបស់អង្គការសុខភាពពិភពលោកក្នុងការបញ្ចប់អេដស៍នៅកម្ពុជាៈ ឱ្យមានការធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯង (HIVST) ជាមធ្យោបាយមួយដើម្បីឈានទៅរកអ្នកផ្ទុកមេរោគអេដស៍ហើយជួយសម្រេចបានគោលដៅ ៩០-៩០-៩០។
- សេចក្តីណែនាំស្តីពីកញ្ចប់សេវា អ៊ីមស្ពាយ និងស្រីស្រស់
- សកម្មភាពអ្នកអប់រំតាមមូលដ្ឋាន
- យុទ្ធសាស្ត្រ និងវិធីសាស្ត្រក្នុងការទប់ស្កាត់ការឆ្លងមេរោគអេដស៍ ក្នុងចំណោមបុរសស្រឡាញ់បុរស និងក្រុមគ្រួសារ។

ជាកិច្ចបន្តឯកឧត្តមប្រធានអង្គប្រជុំ បានស្នើឱ្យក្រសួង ស្ថាប័ន និងអង្គការសង្គមស៊ីវិល ផ្ញើរបាយការណ៍សកម្មភាព មកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឱ្យបានទាន់ពេលវេលា សម្រាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍រួមប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ឯកឧត្តមប្រធានអង្គប្រជុំ ក៏បានជម្រាបជូនដល់សមាជិក សមាជិកានៃអង្គប្រជុំថា **កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី៤ នឹងប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៨**។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១១ និង២០នាទី ថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត៕

**ឧបសម្ពន្ធ៖**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ថ្ងៃចន្ទ ២រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ភ្នំពេញ ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨

| បានឃើញ និងឯកភាព | បានពិនិត្យត្រឹមត្រូវ | អ្នកធ្វើរបាយការណ៍ |
|---|---|---|
| **អគ្គលេខាធិការ** | ប្រធាននាយកដ្ឋាន<br>ទាក់ទង និងចលនាប្រភពធនធាន | |